# ការតាក់តែងច្បាប់ប្រឆាំងអំពើពុករលួយដែលមានប្រសិទ្ធភាព

*"យុត្តិធម៌ក្លាយទៅជាពាក្យដែលគ្រាន់បន្លឺឡើងអោយពិរោះស្តាប់ កាលណាមានជនស៊ីសំណូក ហើយ ការសំរេចរបស់គេកាន់តែអាក្រក់ កាលណាជនទាំងនោះស្ថិតនៅក្នុងអង្គជំនុំជំរះ"*

នៅពេលដែល Hesiod បានរកឃើញថាចៅក្រមពុករលួយម្នាក់បានសំរេចឱ្យដកហូតទ្រព្យសម្បត្តិ របស់គាត់ គាត់មានការតវ៉ាតែមួយគត់គឺត្រូវចងចាំនូវការបរាជ័យក្នុងសារណារបស់គាត់ ។ ប៉ុន្តែដោយចំនួនជន ដែលរងគ្រោះដោយសារមន្ត្រីពុករលួយកាន់តែកើនឡើង គេបានចាប់ផ្តើមទាមទារអោយរដ្ឋាភិបាល ចាត់វិធានការ ។

ជំហានជាក់ស្តែងដំបូងគឺការធានាអោយមានច្បាប់ដើម្បីបង្ក្រាបអំពើពុករលួយ។ ការអនុវត្តន៍ច្បាប់ មិនមែនជាអាទិភាពទីមួយ ឬវិធីការពារដែលត្រូវការចាំបាច់នោះឡើយ ។ ការអប់រំពលរដ្ឋវិទ្យាពិស្តារនិងត្រឹមត្រូវ មន្ត្រីរដ្ឋាភិបាលគោរពក្រមសីលធម៌ការងារ និងវិធានការផ្សេងទៀត អាចកាន់តែមានប្រសិទ្ធភាពក្នុងការប្រឆាំង និងអំពើពុករលួយ ។ ប៉ុន្តែត្រូវប្រើពេលវេលាដើម្បីសំរេចគោលបំណងនេះបាន ក្នុងន័យនេះ ការអនុម័តច្បាប់ប្រឆាំងអំពើពុករលួយត្រូវតែជាមធ្យោបាយមួយដែលឆាប់រហ័ស និងចំណាយតិច ដើម្បីថែង ពីបញ្ហាអំពើពុករលួយ ។

ជាក់ស្តែង មានការរីកសាយច្បាប់ជាច្រើនដែលដាក់ទណ្ឌកម្មលើអំពើសំណូក និងអំពើពុករលួយក្នុងរូបភាពផ្សេងទៀត នៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ (Ofosu-Amaah, Soopramanien, and Uprey 1999) ។ ទោះបីជាច្បាប់ថ្មីទាំងនេះបង្ហាញនូវការប្តេជ្ញាហ្មឹងម៉ាត់ក្នុងការលុបបំបាត់អំពើពុករលួយក៏ដោយ ច្បាប់ទាំងនេះតែងតែមិនបានឆ្លុះបញ្ចាំងនូវសមត្ថភាពមានកំរិតរបស់ស្ថាប័នអនុវត្តឡើយ រួមមានស្ថាប័ននគរបាល ព្រះរាជាអាជ្ញា ឬទីភ្នាក់ងាររដ្ឋបាលដែលមិនមែនជាស្ថាប័នព្រហ្មទណ្ឌជាដើម ។ គំនិតផ្តួចផ្តើមប្រឆាំងអំពើពុករលួយជាច្រើនបានមើលរំលងនូវកំណែទម្រង់ច្បាប់ដែលអាចទប់ស្កាត់ ឬលាតត្រដាងអំពើពុករលួយ ។

## ការផ្សព្វផ្សាយច្បាប់ទៅនិងសមត្ថភាពអនុវត្តន៍

ច្បាប់ប្រឆាំងអំពើពុករលួយនិងច្បាប់ក្រមសីលធម៌ តែងតែចែងបទប្បញ្ញត្តិទាំងឡាយដែលហាមឃាត់អំពើ សំណូក ញាតិនិយម ទំនាស់ផលប្រយោជន៍ ការនិយមផ្តល់កិច្ចសន្យា ឬផ្តល់ផលប្រយោជន៍រដ្ឋាភិបាល ។ ច្បាប់ទាំងនោះតែងតែតម្រូវអោយមន្ត្រីរាជការប្រកាសពីប្រាក់ចំណូលនិងទ្រព្យសម្បត្តិរបស់គេផងដែរ ។ ក្នុងពេលរៀបចំសេចក្តីព្រាងច្បាប់បែបនេះ ចំណុចសំខាន់គឺត្រូវវាយឈ្មោះរាល់សកម្មភាពដែលអាចនឹងចាត់ទុកថាជាអំពើពុករលួយ ហើយសរសេរក្នុងច្បាប់ថាជាអំពើទាំងនោះខុសច្បាប់ ។ ប៉ុន្តែបុគ្គលតែងតែមានគំនិត រស់រវើកគ្មានទីបំផុតក្នុងការរកច្រកដើម្បី

ធ្វើខ្លួនគេ ឬមិត្តភក្តិ ឬគ្រួសារមានបានដោយសារទ្រព្យសម្បត្តិ សាធារណៈ ។ ដោយសារអ្នកតាក់តែងច្បាប់បានដឹងពីបញ្ហានេះ គេតែងតែសរសេរវិធានដែលកាន់តែមានលក្ខណៈទូទៅ ។ សរុបមក គេតែងតែទទួលបានបទប្បញ្ញត្តិទូលំទូលាយដែលស្រង់ចេញស្តង់ដារទូទៅ ដូចជា បទប្បញ្ញត្តិដែលចែងនៅក្នុងច្បាប់របស់ប្រទេសមួយចំនួន ដែលចែងថា "ការប្រើមុខងារសាធារណៈ ដើម្បីផលប្រយោជន៍ផ្ទាល់ខ្លួន" ជាបទព្រហ្មទណ្ឌ ។

ភាសាច្បាប់ត្រង់ចំណុចនេះពិតជាបានលើកឡើងនូវអំពើសំណូកញាតិនិយម និងទំនាស់ផល ប្រយោជន៍ ។ ប៉ុន្តែអ្នកប្រឆាំងនិងការិយាធិបតេយ្យ និងនយោបាយ ក៏អាចលើកឡើងពីបញ្ហានៃការអនុវត្តន៍ អោយសុក្រិតផងដែរ ។ បើមន្ត្រីដែលទទួលបន្ទុកស៊ើបអង្កេតរឿងក្តីមួយពោរពេញទៅដោយផលប្រយោជន៍ បុគ្គល បើកអោយមានសម្ពាធនយោបាយ ឬភ័យខ្លាចមានការរិះគន់ពីចំណុចខ្សោយលើអំពើពុករលួយ ការចោទប្រកាន់គ្មានមូលហេតុ អាចមានឥទ្ធិពលជំរុញដល់នីតិវិធីរឿងក្តីតុលាការ និងនីតិវិធីរដ្ឋបាលបាន ។ បើស្ថាប័នតុលាការ និងរដ្ឋបាលគ្មានអព្យាក្រឹត្យភាព ឬគ្មានសមត្ថភាព នោះយើងមិនអាចកាត់ផ្តាច់រឿងក្តី ដែលសំរេចបត់បែន ទៅតាមអំណាចពីខាងក្រៅបានឡើយ ។ ថ្វីបើមានការលើកលែងការចោទប្រកាន់ក្តី ក៏ការបន្ទាយពេលស៊ើបអង្កេតអាចក្លាយទៅជាទណ្ឌកម្មធ្ងន់ធ្ងរបានដែរ ។

**ច្បាប់ប្រឆាំងអំពើពុករលួយគឺជាចំណុចចាប់ផ្តើមដ៏ល្អមួយ ប៉ុន្តែច្បាប់នោះគួរតែត្រូវបានគេផ្សាភ្ជាប់ទៅនឹងសមត្ថភាពអនុវត្តន៍ និង ត្រូវបានគាំទ្រដោយកំណែទំរង់ច្បាប់នានា**

អាស្រ័យហេតុនេះ អ្នកតាក់តែងច្បាប់ប្រឆាំងអំពើពុករលួយត្រូវតែសួរសំណួរជាច្រើនដូចទៅនេះ : តើស្ថាប័នដែលអនុវត្តមានសមត្ថភាពក្នុងការអនុវត្តន៍ច្បាប់នេះឬទេ? តើស្ថាប័ននរគបាល អយ្យការ តុលាការ និងស្ថាប័នអនុវត្តផ្សេងទៀតមានបុគ្គលិកដែលស្មោះត្រង់ និងសមត្ថភាពខាងវិជ្ជាជីវៈឬទេ? តាមទ្រឹស្តី តើពួកគេឯករាជពីស្ថាប័ននីតិប្រតិបត្តិឬទេ ? ក្នុងការអនុវត្តន៍ជាក់ស្តែង តើពួកគេត្រូវទទួលខុសត្រូវចំពោះ មុខអ្នកណា? ជាញឹកញាប់គេនឹងគ្មានការធានា ចំពោះចម្លើយទៅនិងសំណួរទាំងនេះទេ ។ ក្នុងប្រទេសជាច្រើន ស្ថាប័នអនុវត្តខ្វះអ្នកប្រកបវិជ្ជាជីវៈដែលមានជំនាញ ។ ម្យ៉ាងទៀត បុគ្គលិកនៃស្ថាប័នទាំងនោះ តែងតែ ត្រូវបានអូសទាញអោយបំរើផលប្រយោជន៍នយោបាយដោយងាយស្រួល ។ តាមពិត ការសិក្សារបស់ ធនាគារពិភពលោក បានរកឃើញថា កាលណានគរបាលមានជំនាញទាប និងស្ថាប័នអនុវត្តឯទៀតដែលស្ថាប័នខ្លះពុករលួយខ្លាំង នោះនាំអោយសាធារណជនមានជំនឿតិចបំផុតលើរដ្ឋាភិបាល ។ អ្នកជំនាញខាង កំណែទម្រង់អាចជឿជាក់ថានៃការងារអំពើពុករលួយមិនអាចដើរទៅមុខបានទេលុះត្រាបានពង្រឹងស្ថាប័ន អនុវត្តទាំងនេះ ។ ប៉ុន្តែ ទោះបីជាការកសាងសមត្ថភាពមានការចាំបាច់សំរាប់និរន្តរភាពរយៈពេលវែងនៃកម្មវិធីអំពើពុករលួយក៏ដោយ ក៏ការងារ នេះត្រូវប្រើពេលវេលាដែរ ។

ក្នុងពេលជាមួយគ្នានេះ អ្នកសរសេរច្បាប់ប្រឆាំងអំពើពុករលួយ ត្រូវតែពិចាណាលើចំណុចខ្សោយនៃស្ថាប័នដែលអនុវត្តច្បាប់ដែលខ្លួនកំពុងតាក់តែង ។ ក្នុងករណីភាគច្រើនមានន័យថាសរសេរច្បាប់ដែលងាយយល់ ងាយអនុវត្ត និងតម្រូវអោយមានសេចក្តីសំរេចតិចតួច ឬគ្មានសេចក្តីសំរេចអ្វីក្នុងការកំណត់ពីភាពអាចអនុវត្តបានរបស់ច្បាប់ ។ គេនិយាយថា ការសរសេរច្បាប់តាមរបៀបនេះ មាន "វិធានជាក់លាក់" ដែលផ្ទុយពីច្បាប់ទាំងឡាយដែលចែងពីស្តង់ដារដែលបើកចំហអោយមានការបកស្រាយដោយស្ថាប័នអនុវត្ត (Kaplow 1992) ។

## វិធានជាក់លាក់

តើវិធានច្បាប់ជាក់លាក់អាចលុបបំបាត់ឆន្ទានុសិទ្ធិបកស្រាយរបស់អនុវត្តដោយរបៀបណា? សំណើរបស់ប្រទេស អាហ្សង់ទីនគឺជាឧទាហរណ៍មួយ ។ នៅក្នុងសំណើនេះ គេសង្កេតឃើញថាញាតិនិយម និងបក្សពួកនិយមក្នុងការជ្រើសរើសបុគ្គលិករបស់រដ្ឋាភិបាលគឺជាបញ្ហាធ្ងន់ធ្ងរ ។ សេចក្តីព្រាងច្បាប់គប្បីចែងហាមឃាត់មន្ត្រីរដ្ឋាភិបាល កុំអោយជួលមិត្តភក្តិ ឬសាច់ញាតិលើកលែងតែជននោះ "មានសមត្ថភាព" ចំពោះតំណែងនោះពិតប្រាកដ ។ ប៉ុន្តែប្រសិនបើច្បាប់ទុកអោយតុលាការ និងស្ថាប័នអយ្យការសំរេចថាអ្នកណាមានសមត្ថភាព ពេលនោះស្ថាប័នទាំងនេះនឹងមានអំណាចមហិមាក្នុងការអនុវត្តច្បាប់ ។ សន្មត់ថាច្បាប់បានហាមការជួលមិត្តភក្តិ ឬសាច់ញាតិអោយធ្វើការដោយគ្មានការលើកលែងឬកំណត់សមត្ថភាព ។ ប្រសិនបើច្បាប់មានវិធានជាក់លាក់បែបនេះ នឹងធ្វើអោយអ្នកអនុវត្ត គ្មានឆន្ទានុសិទ្ធិឬទេ ។ វិធានបែបនេះ នឹងធ្វើអោយមានការងាយស្រួលក្នុងការពិនិត្យមើលការគោរព និងការអនុវត្តន៏ច្បាប់ ។ បើការជួលសាច់ញាតិអោយធ្វើការជាអំពើខុសច្បាប់ ហើយក្មួយប្រុសរបស់មន្ត្រីនឹងមានឈ្មោះនៅក្នុងតារាងបៀវត្សរ៍ភ្លាមៗ ការបំពានក្រមសីលធម៌នឹងមានភាពច្បាស់លាស់ ។ ម្យ៉ាងវិញទៀតបើច្បាប់ចែងពីវិធាន លើកលែងចំពោះបុគ្គល "ដែលមានសមត្ថភាព" នោះនឹងបន្តអោយមានការជជែកដេញដោលគ្មានទបញ្ចប់អំពីសមត្ថភាព របស់ក្មួយនោះ ដែលពោរពេញដោយសំណួរជាច្រើន ។ បើច្បាប់ចែងនូវវិធានជាក់លាក់ ពលរដ្ឋ បណ្តាញព័ត៌មាន និង ក្រុមអ្នកឃ្លាំមើល មានការងាយស្រួលក្នុងការកំណត់ថាតើរដ្ឋាភិបាលយកចិត្តដាក់កំរិតណាចំពោះការអនុវត្តន៏ច្បាប់ ប្រឆាំងនិងអំពើពុករលួយ ។ វិធានជាក់លាក់ មិនមែនគ្មានតម្លៃនោះឡើយ ។ ចំណុចទីមួយវាបំបាត់វិធានច្បាប់ដែលអាចបត់បែនបាន ។ ក្នុងករណីច្បាប់ប្រឆាំងអំពើពុករលួយ រដ្ឋាភិបាលអាចនឹងត្រូវបាត់បង់មនុស្សប្រសើរបំផុតពីការងារ បើជននោះជាប់សាច់ញាតិនិងអ្នកណាម្នាក់ដែលធ្វើការនៅនាយកដ្ឋានពាក់ព័ន្ធណាមួយ ។ ចំណុចទីពីរ វិធានជាក់លាក់ នេះត្រូវតែចែងអោយបានសាមញ្ញដល់ឬសគល់ដែលប្រឆាំង ពោលធ្វើអោយមានការលំបាក ទទួលយកជាងស្តង់ដារប្រើពាក្យទូលាយ ដែលតែងតែស្របទៅនិងការយល់ដឹងរបស់សង្គម ។ ប៉ុន្តែក្នុង

> **ប្រទេសដែលមានស្ថាប័នអនុវត្តខ្សោយ គួរតែពិចារណានូវការដាក់បញ្ចូលនូវវិធានការជាក់លាក់នៅក្នុងច្បាប់ប្រឆាំងនឹងអំពើពុករលួយរបស់ខ្លួន**

ប្រទេសដែល មានប្រព័ន្ធច្បាប់ខ្សោយ តុលាការអាចមានការលំបាកនឹងអនុវត្តស្តង់ដារអោយមានប្រសិទ្ធិភាព (Hay and Shleifer 1998) ។ ក្រៅពីនេះ តម្លៃនៃវិធានជាក់លាក់តែងតែច្រើនជាងបើទូទាត់និងតម្លៃនៃការទប់ស្កាត់ និងតម្លៃនៃការសំរួល ការតាមដាននៅក្នុង ប្រទេសទាំងឡាយដែលមានទីភ្នាក់ងារអនុវត្តខ្សោយ (Posner 1998) ។ ប្រទេសដែលមានស្ថាប័ន អនុវត្តខ្សោយ ត្រូវពិចារណាលើវិធានជាក់លាក់ដូចខាងក្រោមនេះ :

- គ្មានមន្ត្រីរដ្ឋាភិបាលណាម្នាក់អាចទទួលអំណោយ ការបង់ប្រាក់ ឬរបស់អ្វីមួយដែលមានតម្លៃលើសពីទឹកអប្បបរមា ពីបុគ្គលណាម្នាក់ដែលមិនមែនជាសមាជិកក្នុងគ្រួសាររបស់ខ្លួនឡើយ ។
- គ្មានមន្ត្រីណាម្នាក់អាចកាន់កាប់ផលប្រយោជន៍ក្នុងក្រុមហ៊ុន ឬស្ថាប័នដទៃទៀតដែលរងឥទ្ធិពលពីសេចក្តីសំរេច របស់ខ្លួន ទោះបីជាដោយផ្ទាល់ឬដោយប្រយោល (តាមរយៈគ្រួសារ ឬភ្នាក់ងារ)ក្តី ។
- ជារៀងរាល់ឆ្នាំ មន្ត្រីដែលទទួលបៀវត្សរ៍ខ្ពស់ជាងកំរិតកំណត់ ត្រូវតែប្រកាសជាសាធារណៈពីទ្រព្យសម្បត្តិ ទាំងអស់ដែលខ្លួនកាន់កាប់ដោយផ្ទាល់ ឬដោយប្រយោលក្តី ។
- គ្មានមន្ត្រីណាអាចជួលសាច់ញាតិបានឡើយ (ត្រូវមានលក្ខណៈវិនិច្ឆ័យជាក់លាក់អំពីតំណសាច់ញាតិឆ្ងាយប៉ុណ្ណា ដែលមិនត្រូវចាត់ទុកថាជា "សាច់ញាតិ") ។
- មន្ត្រីទាំងអស់ត្រូវតែប្រកាសពីទំនាក់ទំនងជាមួយមនុស្សដែលខ្លួនជួល និងជាមួយក្រុមហ៊ុន ឬអង្គភាពដែលខ្លួនផ្តល់ ត្រូវកិច្ចសន្យា ឬសម្បទានអោយ ។(ដោយសារប្រទេសជាច្រើន មានកម្មករជំនាញច្រើននិងក្រុមហ៊ុនមាន សមត្ថភាពតិចតួច វិធាននេះទុកអោយសាធារណជនជាអ្នកសំរេចពីបញ្ហា "អំពើពុករលួយ")។

## វិធានការណ៍បន្ថែម

> ច្បាប់ដែលចាត់ទុកថាសំណូកញាតិបក្សនិយម និងអំពើពុករលួយឯទៀតជាអំពើខុសច្បាប់ គប្បីបំពេញបន្ថែមដោយច្បាប់ដែលជួយលាតត្រដាងអំពើពុករលួយ

គ្មានច្បាប់ណាដែលអាចជៀសវាងបទប្បញ្ញត្តិខ្លះដែលបង្ករការសង្ស័យបានទេ ។ កាលណាបញ្ញត្តិមួយនៅក្នុងច្បាប់ ប្រឆាំងនិងអំពើពុករលួយ ត្រូវតែចំណុចណាមួយដែលចំហអោយមានការបកស្រាយមធ្យោបាយមួយសំរាប់កាត់បន្ថយ ឆន្ទានុសិទ្ធិរបស់អ្នកអនុវត្តគឺការបង្កើតនីតិវិធីសំរាប់ទទួលការសំរេចជាមុន ។ មន្ត្រីដែលមានចម្ងល់ពីករណីសង្ស័យ អាចសាកសួរមកអ្នកតំណាងអង្គភាពអនុវត្តដែលអាចស្ថិតនៅក្នុងស្ថាប័នរបស់គេ ដើម្បីទទួលបានការសំរេចជាមុនពីនីត្យានុកូលភាពនៃសេចក្តីសំរេចដែលត្រូវធ្វើ ។ យោងតាមអង្គហេតុដែលទទួលបាន បើអាជ្ញាធរអនុវត្តសន្និដ្ឋាន ថាវិធានការដែលគ្រោងនឹងមិនបង្កើតនូវការបំពានទេ មន្ត្រីសំរេចនោះនឹងរួចផុតពីការចោទប្រកាន់នាពេលអនាគត ។ ដើម្បីជៀសវាងដំណើរការដែលពន្យាពេលសេចក្តីសំរេចរដ្ឋដែលមិនសមស្រប ច្បាប់អាចតម្រូវអោយតំណាងស្ថាប័ន សំរេចតាមសំណើរក្នុងកំឡុងពេលដែលបានកំណត់ ។

បើគេមិនបានធ្វើដូច្នោះទេ ច្បាប់ អាចចែងតម្រូវថាសេចក្តីសំរេច ក្នុងករណីនេះគឺស្របច្បាប់ ។

នៅពេលអនុវត្តជំហានដំបូង ទីភ្នាក់ងារអាចប្រឈមនិងការកកស្ទះបណ្តឹងតវ៉ាសុំជំនួយជាច្រើន ។ ប៉ុន្តែជាបន្តបន្ទាប់មក មតិយោបល់ដ៏ច្រើនរបស់គេនឹងក្លាយទៅជាអង្គច្បាប់ ដែលណែនាំដល់តុលាការ និងអ្នកដែលត្រូវគោរពតាមគោលការណ៍ណែនាំខាងក្រមសីលធម៌ ។ នីតិវិធីផ្តល់ការសំរេចជាមុន ក៏អាចបង្វែរអ្វីដែលអាចជាទំនាក់ទំនងប្រតិបក្សអោយទៅជាទំនាក់ទំនងសហការបានដែរ ដោយមន្ត្រីនោះធ្វើការជាមួយមន្ត្រីក្រមសីលធម៌ ក្នុងការកំណត់ដំណើរការអោយស្របទៅតាមច្បាប់ ។ ក្រៅពីនេះ បើក្រោយមកគេរកឃើញថាសេចក្តីសំរេចមួយចោទជាបញ្ហា ដែលមិនស្របទៅតាមការសំរេចជាមុន ពេលនោះនឹងបង្ហាញមុខបុគ្គលដែលចុះហត្ថលេខាបញ្ជាក់ពីបំណងជៀសវាងច្បាប់ ។

ច្បាប់ដែលចាត់ទុកថាសំណូក ញាតិបក្សនិយម និងអំពើពុករលួយឯទៀតជាអំពើខុសច្បាប់ គប្បីបំពេញបន្ថែមដោយច្បាប់ដែលជួយលាតត្រដាងអំពើពុករលួយ ។ ច្បាប់ស្តីពីសេរីភាពសារព័ត៌មានគឺជាឧទាហរណ៍មួយ ។ ច្បាប់នេះតម្រូវអោយរដ្ឋាភិបាលប្រកាសពីសកម្មភាពរបស់ខ្លួនតាមសំណើរបស់ពលរដ្ឋណាម្នាក់ ហើយក្រុមតាមឃ្លាំមើលអាចយកទៅប្រើដើម្បីតាមដានអាកប្បកិរិយារបស់រដ្ឋាភិបាល (Blaton 2001)។ ដូចគ្នានេះដែរ ក្នុងប៉ុន្មានឆ្នាំថ្មីៗនេះ ប្រទេសមួយចំនួនបានអនុម័តច្បាប់ស្តីពីការការពារអ្នកផ្តល់ព័ត៌មាន ដើម្បីលើកទឹកចិត្តអោយមន្ត្រីរដ្ឋាភិបាលបង្ហាញការពិតពីអំពើពុករលួយដែលលាក់កំបាំងក្នុងពេលគេបំពេញការងារ ដោយមិនគ្មានការភ័យខ្លាចការសងសឹក (Hall and Davies 1999/ Pack 2001)។

កំណែទម្រង់ច្បាប់ស្តីពីការបរិហាកេរ្តិ៍ក៏ជាផ្នែកសំខាន់មួយដែរសំរាប់ការតាក់តែងច្បាប់ប្រឆាំងអំពើពុករលួយ ។ ច្បាប់របស់ប្រទេសខ្លះចាត់ទុកការបោះពុម្ពផ្សាយអ្វីមួយដែលធ្វើអោយខូចកិត្តិយសរដ្ឋាភិបាល ឬមើលងាយមន្ត្រីរដ្ឋាភិបាលជាបទល្មើសព្រហ្មទណ្ឌ ។ តាមច្បាប់នេះ អ្នកសារព័ត៌មានដែលចោទសរសេរថាមន្ត្រីណាម្នាក់ទទួលសំណូក ឬប្រព្រឹត្តិអំពើពុករលួយផ្សេងទៀត អាចត្រូវបានផាកពិន័យ និងដាក់ពន្ធនាគារ ដោយមិនគិតថាការចោទប្រកាន់នោះពិតឬមិនពិតឡើយ ។

ដើម្បីធានាកុំអោយសារព័ត៌មានមានការភ័យខ្លាចការចោទប្រកាន់ដោយសារការបញ្ចេញមតិនេះ ច្បាប់របស់ប្រទេសឧស្សាហកម្មលូតលាស់ បានកំណត់វិធានដែលធ្វើអោយមន្ត្រីរដ្ឋាភិបាលពិបាកនឹងប្តឹងរកដំណោះស្រាយ កាលណាសារពតិមានបានសរសេរបរិហាកេរ្តិ៍ (World Bank 2001, Schwartz 1996)។ ប្រទេសនីមួយៗអាចកំណត់ការថ្លឹងថ្លែងខុសៗគ្នារវាងការការពារកិត្តិយសរដ្ឋាភិបាល មន្ត្រីរដ្ឋាភិបាល និងការអនុញ្ញាតអោយអ្នកកាសែតសរសេរអំពីអាកប្បកិរិយាពុករលួយ ។

នៅទីបញ្ចប់ការមានច្បាប់ជាតិតែមួយមិនមែនជាឱសថសំរាប់ព្យាបាលជម្ងឺគ្រប់មុខទេ យើងក៏ត្រូវការកិច្ចសហប្រតិបត្តិការអន្តរជាតិផងដែរ ។ ក្នុងករណីមានការពាក់ព័ន្ធនិងប្រាក់ច្រើន ការប្រមូលមូលនិធិទាំងនោះមកវិញច្រើនតែបង្កនូវបញ្ហា ដោយសារមន្ត្រីពុករលួយអាចលាក់ទ្រព្យនៅបរទេសបាន ។ សន្ធិសញ្ញាគប្បីចែងអនុញ្ញាតអោយប្រទេសដែលស្នើសុំមានសិទ្ធិខ្ពស់ជាងច្បាប់ស្តីពីការរក្សាការសម្ងាត់ធនាគារ និងឧបសគ្គផ្សេងទៀតដើម្បីអោយប្រទេសនោះអាចប្រមូលប្រាក់បាន ។ *សៀវភៅប្រភពច្បាប់* តម្លាភាពអន្តរជាតិ (ឆ្នាំ២000) បានកំណត់នូវកំណែទម្រង់មួយចំនួន ដែលត្រូវមានដើម្បីបំបាត់អំពើពុករលួយ ។ ក្នុងខណៈដែលការសិក្សាក្នុងវិស័យនេះចេះតែរីកចំរើន ចំនួនកំណែទម្រង់ដែលចាំបាច់ចេះតែកើនឡើងជាដរាប ។

ក្នុងរយៈពេលដប់ឆ្នាំកន្លងមកនេះ គេបានប្រមូលផ្តុំកត្តាមួយចំនួនដើម្បីកំណត់អោយបានច្បាស់ថា អំពើពុករលួយជាបរបៀវារៈសកលលោក ។ ដោយសារមានសម្ពាធពីសង្គមស៊ីវិល និងការកើនឡើងនូវលិខិតុបករណ៍ដែលសរសេរពីផលអវិជ្ជមានដែលរារាំងការអភិវឌ្ឍន៍ ទើបអ្នកធ្វើគោលនយោបាយ បានងាកទៅទទួលស្គាល់សេចក្តីសង្កេត ចាស់របស់ Hesiod វិញ ។

**ដើម្បីកំចាត់អំពើពុករលួយក្នុងរដ្ឋាភិបាល អាចតម្រូវអោយមានកំណែទម្រង់ស៊ីជំរៅ ជាប្រព័ន្ធមួយ ។ ប៉ុន្តែទៅបីជាជំហានតិចតួចក៏ដោយក៏អាចជួយបានដែរ**

ចូរគោរពយុត្តិធមិ ហើយកុំប្រព្រឹត្តអំពើកំហុសដោយប្រមាថ ដោយសារអំពើកំហុសនេះបង្កការអន្តរាយដល់ជនក្រីក្រ ហើយសូម្បីតែអភិជនក៏យល់ថាអំពើពុករលួយជាបន្ទុកដែលគេមិនចង់ជួប និងធ្វើអោយគេធ្លាក់ចុះ និង អន្តរាយ ។

ដើម្បីកំចាត់អំពើពុករលួយក្នុងរដ្ឋាភិបាល អាចតម្រូវអោយមានកំណែទម្រង់ស៊ីជំរៅ ជាប្រព័ន្ធមួយ ។ ប៉ុន្តែកំណែទម្រង់ ច្បាប់ដូចបាន រៀបរាប់ខាងលើ ផ្តល់នូវមធ្យោបាយដោយផ្ទាល់ និងចំណាយតិច ដើម្បីជាជំហានដំបូងឆ្ពោះទៅរកការ កាត់បន្ថយអំពើពុករលួយដែលបានយាយីប្រទេសជាច្រើន ។

**ចូរអានឯកសារយោងបន្ថែម..............**

ច្បាប់ប្រឆាំងអំពើពុករលួយជាចំណុចចាប់ផ្តើមដ៏ល្អមួយ ប៉ុន្តែត្រូវតែផ្សារភ្ជាប់ទៅនឹងសមត្ថភាពអនុវត្ត និងជំរុញដោយកំណែទម្រង់ច្បាប់ ។

ប្រទេសដែលមានស្ថាប័នអនុវត្តខ្សោយ គប្បីពិចារណាប្រើច្បាប់ប្រឆាំងអំពើពុករលួយដែលមានវិធានជាក់លាក់ ។

ច្បាប់ដែលចាត់ទុកថាសំណូក ញាតិបក្សនិយម និងអំពើពុករលួយឯទៀតជាអំពើខុសច្បាប់ គប្បីបំពេញបន្ថែម ដោយច្បាប់ដែលជួយលាតត្រដាងអំពើពុករលួយ

ដើម្បីកំចាត់អំពើពុករលួយក្នុងរដ្ឋាភិបាល អាចតម្រូវអោយមានកំណែទម្រង់ស៊ីជំរៅជាប្រព័ន្ធមួយ ប៉ុន្តែសូម្បីជំហានតូចៗរួមគ្នាក៏អាចជួយសំរាលបានដែរ ។